សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការរៀបចំខ្លួនដើម្បីចេញទៅធ្វើការ ដែលរូបភាពទី ១
យើងឃើញមានស្ត្រីម្នាក់កំពុងតែគេងលក់យ៉ាងស្រួលនៅលើគ្រែក្នុងបន្ទប់គេងរបស់គាត់។
អញ្ចឹងយើងឃើញនៅក្នុងបន្ទប់គេងរបស់គាត់ យើងឃើញមានគ្រែមួយ
ដែលគ្រែរបស់គាត់គឺដាក់នៅជាប់នឹងជញ្ជាំងក្បែរនឹងបង្អួចកញ្ចក់។
យើងឃើញបង្អួចកញ្ចក់របស់គាត់មានវាំងននសងខាង ប៉ុន្តែគាត់មិនបានបិទវាំងនននោះទេ។
ដូច្នេះនៅពេលព្រឹកនៅពេលដែលមាន នៅពេលព្រឹកនៅពេលដែលព្រះអាទិត្យរះ
ពន្លឺព្រះអាទិត្យនឹងជះចូលទៅក្នុងបន្ទប់គេងរបស់គាត់។ ប៉ុន្តែនៅក្នុងរូបភាពទីមួយ
គឺនៅក្នុងរូបភាពទីមួយ គឺគាត់កំពុងតែគេងលក់យ៉ាងស្រួលនៅលើគ្រែ
ដោយយើងឃើញនៅក្បែរក្បាលគ្រែរបស់គាត់ យើងឃើញមានកូនតុតូចមួយ ដែលមានមួយថត
និងនៅលើកូនតុនោះយើងឃើញមាននាឡិការោទ៍ ដែលនាឡិការោទ៍គឺប្រើសម្រាប់កំណត់ពេលវេលា
ឬក៏ដាក់ម៉ោង ឬក៏ដាក់ ឬក៏ដាក់ម៉ោង ឬក៏ពេលណាមួយដែលយើងចង់ឲ្យវារោទ៍
ដូច្នេះនាឡិកានោះនឹងរោទ៍ដើម្បីប្រ[ញ្ចាក់] នឹងរោទ៍បញ្ចេញសំឡេងដើម្បីប្រាប់យើង
អញ្ចឹងនាឡិការោទ៍គឺគាត់ដាក់នៅលើតុក្បែរនឹង ក្បែរនឹងក្បាលគ្រែរបស់គាត់ ឬក៏ក្បែរខ្លួនរបស់គាត់។
អញ្ចឹងយើងឃើញនាឡិកានោះ យើងឃើញនាឡិកានោះកំពុងតែរោទ៍
ដោយសារពេលនេះគឺជាពេលព្រឹក គាត់ត្រូវ[ភ្ញាក់] គាត់ត្រូវក្រោកដើម្បី
គាត់ត្រូវក្រោកដើម្បីទៅធ្វើការឲ្យទាន់ពេលវេលា។

រូបភាពទីពីរ ក្រោយពេលដែលនាឡិកានោះរោទ៍ហើយ គាត់ក៏បានក្រោក ឬក៏គាត់ក៏បានភ្ញាក់ដឹងខ្លួន
និងក្រោក ប៉ុន្តែគាត់នៅអង្គុយនៅលើគ្រែនៅឡើយទេ គាត់មិនទាន់ក្រោកចេញពីគ្រែរបស់គាត់ទេ
អញ្ចឹងគាត់អង្គុយនៅលើគ្រែរបស់គាត់ អញ្ចឹងគាត់គ្រាន់តែក្រោក និងងើបចេញពីភួយ
និងអង្គុយនៅលើគ្រែ អញ្ចឹងយើងឃើញគាត់ស្លៀកពាក់ខោអាវគេងយប់
យើងឃើញខោអាវរបស់គាត់គឺលក្ខណៈជាខោអាវឈុត ខោអាវឈុតដែល[មាន]
ដែលយើងឃើញអាវកមូលដៃវែង និងមានឡេវមួយជួរនៅខាងមុខ និងមានកូនហោប៉ៅតូចមួយនៅ
នៅខាងស្តាំដៃរបស់ នៅខាងស្តាំដៃរបស់គាត់ និងដៃខាងឆ្វេងរបស់គាត់គឺ គាត់លើកឡើង
ដោយសារតែគាត់ស្វាប និងនៅពេលដែលស្វាបគឺមាត់របស់យើងហាធំ ដូច្នេះគឺគាត់លើក[ដៃ]
គឺគាត់យកដៃរបស់គាត់ដើម្បីបិទមាត់របស់គាត់នៅពេលដែលគាត់ស្វាប
អញ្ចឹងនៅពេលដែលគាត់ក្រោកពីគេងគាត់ គាត់ត្រូវងើប និងអង្គុយនៅលើគ្រែបន្តិចសិនដើម្បីពត់ខ្លួន
ដើម្បីពត់ខ្លួន ពីព្រោះពេលខ្លះនៅពេលដែលយើងគេង ក្រោក
នៅពេលដែលយើងទើបតែក្រោកពីគេង មានអារម្មណ៍ថាស្ពឹកខ្លួន
ឬក៏មានអារម្មណ៍ថាឈឺខ្លួនបន្តិចបន្តួច ដូច្នេះនៅពេលដែលក្រោកយើងត្រូវពត់ខ្លួនបន្តិចសិន ពត់ខ្លួន
ឬក៏ស្វាបបន្តិចសិន មុនពេលទៅ មុនពេលចូលទៅក្នុងបន្ទប់ទឹក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ក្រោយពេលដែលគាត់ក្រោក ក្រោកពត់ខ្លួនមួយសន្ទុះហើយ គាត់ក៏បានឱនទៅបិទនាឡិការោទ៍របស់គាត់ដែលដាក់នៅលើតុនោះ អញ្ចឹងយើងឃើញគាត់ឱនបិទនាឡិការោទ៍របស់គាត់ ដោយដៃខាងស្តាំរបស់គាត់ដាក់នៅលើជង្គង់ ដៃខាងឆ្វេង គឺគាត់ឱនទៅចុច ឱនទៅចុចបិទ ឱនទៅចុចកុងតាក់ដើម្បីបិទ បិទសំឡេងកុំឲ្យនាឡិកា ដើម្បីបិទនាឡិកានោះកុំឲ្យឮសំឡេងរោទ៍ទៀត ដែលនាឡិការបស់គាត់គឺដាក់នៅលើតុ ដាក់នៅលើតុក្បែរ ក្បែរ ក្បែរក្បាលដំណេករបស់គាត់ ឬក៏ក្បែរក្បាលគ្រែ អញ្ចឹងគាត់ឱនបិទនាឡិកានោះ។

បន្ទាប់មកទៀតរូបភាពទី ៤ ក្រោយពេលដែលគាត់ឱនបិទនាឡិកានោះហើយ គាត់ក៏បានក្រោកចេញពីគ្រែ ដើម្បីដើរចូលទៅក្នុងបន្ទប់ទឹក ប៉ុន្តែគាត់មិនទាន់រៀបចំគ្រែគាត់នៅឡើយទេ ប្រហែលជាគាត់រង់ចាំត្រលប់មកពីបន្ទប់ទឹកសិន អញ្ចឹងទើបគាត់មករៀបចំគ្រែរបស់គាត់វិញ អញ្ចឹងយើងឃើញគាត់ស្លៀកពាក់ខោអាវគេងយប់ អញ្ចឹងគាត់កំពុងតែដើរទៅក្នុងបន្ទប់ទឹកដើម្បីដុសសម្អាត និងងូតទឹក ដើម្បីដុសសម្អាតធ្មេញ និងងូតទឹក។

រូបភាពទី ៥ រូបភាពទី ៥ គាត់ក៏បានដើរចូលមកក្នុងបន្ទប់ទឹក ដោយយើងឃើញបន្ទប់ទឹករបស់គាត់មាន បន្ទប់ទឹករបស់គាត់យើងឃើញមានដូចជា យើងឃើញមានដូចជាទូ ឬក៏ យើងឃើញមានដូចជាទូមួយ ដែលដាក់នៅជាប់នឹងជញ្ជាំងខាងលើ ប្រហែលជាទូនោះដាក់ប្រដាប់ប្រដាសម្រាប់សម្អាតធ្មេញ ឬក៏ដាក់ថ្នាំដុសធ្មេញនៅខាងលើនោះ ឬក៏ជាបង្អួចកញ្ចក់មួយដែលដាក់នៅក្នុងបន្ទប់ទឹកនោះ និងយើងឃើញមានកញ្ចក់មួយ ដែលដាក់នៅជាប់នឹងជញ្ជាំង ដោយកញ្ចក់គឺយើងប្រើសម្រាប់ឆ្លុះមុខរបស់យើង និងយើងឃើញមានឡាបូសម្រាប់លាងដៃ និងមានក្បាលម៉ាស៊ីនទឹក។ អញ្ចឹងគាត់កំពុងតែដើរតម្រង់មកកាន់កញ្ចក់ និង និង និងកន្លែងសម្អាតដៃនោះ ដើម្បីដុសសម្អាតធ្មេញរបស់គាត់។

រូបភាពទី ៥ រូបភាព រូបភាពទី ៦ រូបភាពទី ៦ ក្រោយពេលដែលគាត់ដើរចូលមកក្នុងបន្ទប់ទឹក គាត់ក៏បានយកថ្នាំដុសធ្មេញច្របាច់ដាក់នៅលើច្រាសដុសធ្មេញរបស់គាត់ អញ្ចឹងនៅពេលព្រឹកជាទូទៅក្រោយពេលដែលក្រោកពីគេង យើងត្រូវដុសធ្មេញ ដុសសម្អាតធ្មេញ ដោយប្រើថ្នាំដុសធ្មេញ ពីព្រោះថ្នាំដុសធ្មេញអាចជួយឲ្យ អាចជួយបំបាត់ក្លិនមាត់ និងអាចជួយឲ្យធ្មេញរបស់យើងរឹងមាំផងដែរ ពីព្រោះនៅពេលដែលយើងញ៉ាំអាហារ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលយើងញុាំអាហារ ឬក៏ញុាំចំណី ឬក៏ស្ករគ្រាប់ណាមួយ
ដែលងាយស្រួលធ្វើឲ្យធ្មេញរបស់យើងពុក ឬក៏ងាយស្រួលបំផ្លាញធ្មេញរបស់យើង
ដូច្នេះយើងត្រូវប្រើច្រាសដុសធ្មេញដែលល្អ និងថ្នាំដុសធ្មេញដែលល្អ ដើម្បីជួយសម្អាតនូវ
ជួយសម្អាតនូវ ចំណីអាហារទាំងអស់នោះដែលមានជាប់នៅធ្មេញរបស់យើង
និងដើម្បីជួយការពារធ្មេញរបស់យើងឲ្យរឹងមាំផងដែរ។ អញ្ចឹងយើងឃើញគាត់កាន់ថ្នាំដុសធ្មេញ
និងច្របាច់ថ្នាំដុសធ្មេញដាក់នៅលើច្រាសរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ គាត់ក៏
ក្រោយពេលដែលគាត់ដាក់ថ្នាំដុសធ្មេញនៅលើច្រាសដុសធ្មេញរបស់គាត់រួចរាល់ហើយ
គាត់ក៏បានយកច្រាសដុសធ្មេញនោះដាក់ចូលទៅក្នុងមាត់របស់គាត់
ដើម្បីដុសសម្អាតធ្មេញរបស់គាត់។ ដោយសារតែគាត់មាន
ដោយសារតែគាត់មានដាក់ថ្នាំដុសធ្មេញនៅលើច្រាសរបស់ ច្រាសដុសធ្មេញរបស់គាត់
ដូច្នេះនៅពេលដែលគាត់កំពុងតែដុសសម្អាតធ្មេញរបស់គាត់ យើងឃើញមានពពុះ
យើងឃើញមានពពុះចេញមកខាងក្រៅ យើងឃើញមានពពុះថ្នាំដុសធ្មេញចេញមកខាងក្រៅ
អញ្ចឹងដោយសារតែគាត់ដាក់ថ្នាំដុសធ្មេញនៅលើច្រាសដុសធ្មេញរបស់គាត់
អញ្ចឹងនៅពេលដែលយើងដុសសម្អាតធ្មេញ ពេលដុសសម្អាតធ្មេញ នឹងមានពពុះចេញមកខាងក្រៅ
អញ្ចឹងយើងឃើញរូបភាពទី ៧ នេះ យើងឃើញគាត់ដុសសម្អាតធ្មេញ
ដែលមានពពុះជាច្រើនចេញមកខាងក្រៅ អញ្ចឹងយើងឃើញដៃខាងឆ្វេងរបស់គាត់ច្រត់ចង្កេះ
ដៃខាងស្ដាំរបស់គាត់កាន់ច្រាសដុសធ្មេញ និងដុសសម្អាតធ្មេញរបស់គាត់ពីលើចុះមកក្រោម
និងមានពពុះចេញមកខាងក្រៅផងដែរ។

រូបភាពទី ៨ ក្រោយពេលដែលគាត់ដុសសម្អាតធ្មេញរួចរាល់ហើយ គាត់ក៏បាន
គាត់ក៏បានយកកែវដាក់ទឹក បន្ទាប់មកគាត់ក៏បានយកទឹកនៅក្នុងកែវនោះខ្ពុរមាត់របស់គាត់
ដើម្បីសម្អាតពពុះ និងដើម្បីសម្អាតកម្ទេចអាហារចេញពីធ្មេញរបស់គាត់ផងដែរ
ប៉ុន្តែជាទូទៅមុនពេលចូលគេងយើងដុសសម្អាតម្ដងហើយ យើងដុសសម្អាតម្ដងហើយ
ដូច្នេះនៅពេលព្រឹកយើងអត់សូវមានកម្ទេចអាហារ ឬក៏នំនៅជាប់នឹងធ្មេញរបស់យើងទេ
ប៉ុន្តែយើងដុសសម្អាត ដើម្បី ដើម្បី ដើម្បីថែទាំធ្មេញរបស់យើងឲ្យរឹងមាំ
និងដើម្បីកុំឲ្យមានក្លិនមាត់ផងដែរ អញ្ចឹងគាត់សម្អាតធ្មេញ គាត់ខ្ពុរមាត់របស់គាត់
គាត់ខ្ពុរមាត់របស់គាត់ ដោយគាត់កាន់កែវទឹក ដោយគាត់កាន់កែវទឹកនៅក្នុងដៃខាងស្ដាំរបស់គាត់
និងដៃខាងឆ្វេងគឺគាត់កាន់ច្រាស គឺគាត់កាន់ច្រាសដុសធ្មេញដែលគាត់បានដុសរួចរាល់ហើយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ក្រោយពេលដែលគាត់ដុសសម្អាតធ្មេញ
និងខ្ពុរមាត់រួចរាល់ហើយ គាត់ក៏បានដោះខោអាវរបស់គាត់
បន្ទាប់មកគាត់ក៏ដើរចូលទៅងូតទឹកនៅក្នុងបន្ទប់ទឹក
ដោយគាត់ងូតទឹកផ្កាឈូកនៅក្នុងបន្ទប់ទឹករបស់គាត់។ អញ្ចឹងយើងឃើញនៅពេលដែលគាត់
នៅពេលដែលគាត់ នៅពេលដែលគាត់
នៅពេលដែលគាត់ចូលទៅងូតទឹកផ្កាឈូកក្នុងបន្ទប់ទឹករបស់គាត់ គាត់ក៏បានយកសាប៊ូមកកក់សក់
មកកក់សម្អាតសក់របស់គាត់ ដើម្បីឲ្យសក់របស់គាត់ទន់រលោង ដើម្បីឲ្យសក់របស់គាត់ទន់រលោង
និងពេលខ្លះដោយសារតែសក់របស់យើងមានញើស និងមានជាតិខ្លាញ់ ដូច្នេះពេលខ្លះធ្វើឲ្យសក់
ធ្វើឲ្យស្បែកក្បាលរបស់យើងរមាស់ និងធ្វើឲ្យសក់របស់យើងរឹងផងដែរ ដូច្នេះគាត់ត្រូវការកក់
ដូច្នេះយើងត្រូវការកក់សម្អាត យើងត្រូវការកក់សក់ ដើម្បីសម្អាតសក់
ឬក៏ដើម្បីសម្អាតស្បែកក្បាលរបស់យើង។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ៩ នោះ
យើងឃើញគាត់បានយកសាប៊ូកក់សក់មកកក់សក់របស់គាត់ និងគាត់បានដុសសម្អាត និងគាត់បាន
និងគាត់បានប្រើសាប៊ូនោះដុសខ្លួនរបស់គាត់ផងដែរ អញ្ចឹងយើងឃើញគាត់កក់សក់បណ្តើរ
គាត់កក់សក់បណ្តើរ គាត់បើកទឹកផ្កាឈូកនោះបណ្តើរ ដើម្បីសម្អាតខ្លួន និងសម្អាតសក់របស់គាត់
អញ្ចឹងយើងឃើញគាត់ ដៃទាំងពីររបស់គាត់អេះក្បាលរបស់គាត់ ដើម្បី
ដើម្បីឲ្យសាប៊ូជ្រាបចូលទៅក្នុងសាច់ សាច់ក្បាលរបស់គាត់។

រូបភាពទី ១០ ក្រោយពេលដែលគាត់កក់សក់ និងសម្អាតខ្លួនជាមួយនឹងទឹកផ្កាឈូក
និងជាមួយនឹងសាប៊ូរួចរាល់ហើយ ខ្លួនរបស់គាត់ និងសក់របស់គាត់ទទឹក
ដូច្នេះគាត់ក៏បានយកកន្សែងពោះគោ ដើម្បីមកជូតសម្អាតសក់ និងខ្លួនរបស់គាត់ឲ្យស្ងួត
ពីព្រោះប្រសិនបើខ្លួននិងសក់ទទឹកនៅពេលដែលគាត់ដើរចេញមកខាងក្រៅ ទឹកនោះនឹងតក់
ឬក៏ហូរចុះមក ហូរធ្លាក់មកខាងក្រោម ដូច្នេះអាចធ្វើឲ្យគាត់ដើររអិលផងដែរ
អញ្ចឹងគាត់ត្រូវជូតសម្អាតខ្លួនរបស់គាត់ជាមុនសិន និងនៅពេលដែលខ្លួនរបស់គាត់សើម
និងបន្ទាប់មកគាត់ស្លៀកពាក់ខោអាវ អញ្ចឹងខោអាវ នឹងធ្វើឲ្យខោអាវរបស់គាត់សើម
និងនៅពេលដែលគាត់ស្លៀកពាក់ខោអាវសើមក៏អាចធ្វើឲ្យគាត់ផ្តាសាយ ឬក៏ឈឺផងដែរ
ដូច្នេះគាត់ត្រូវជូតសម្អាតខ្លួនរបស់គាត់ឲ្យស្ងួត និងជូតសម្អាតសក់របស់គាត់ឲ្យស្ងួតសិន
ដោយប្រើកន្សែងពោះគោ។

និងរូបភាពទី ១១ ក្រោយពេលដែលគាត់ជូតសម្អាតខ្លួនរបស់គាត់ស្ងួតហើយ
គាត់ក៏បានដើរចូលមកក្នុងបន្ទប់គេងរបស់គាត់វិញ
និងរៀបចំគ្រែរបស់គាត់មានសណ្តាប់ធ្នាប់រួចរាល់ហើយ គាត់ក៏បាន គាត់ក៏បានដោះ គាត់ក៏បានដាក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានដោះ និងដាក់អាវ គាត់ក៏បានដោះខោអាវគេងយប់របស់គាត់ និងដាក់វានៅលើ
និងដាក់វានៅលើគ្រែរបស់គាត់ នៅលើគ្រែរបស់គាត់ ដោយយើងឃើញមានខោជើងវែង
និងអាវដៃវែងដែលមានឡេវមួយជួរនៅខាងមុខ និងមានហោប៉ៅតូចមួយនៅខាងស្ដាំអាវនោះ
អញ្ចឹងយើងឃើញគាត់បានដោះអាវនោះដាក់នៅលើគ្រែ ដើម្បីប្ដូរខោអាវចេញទៅធ្វើការ។
អញ្ចឹងក្រោយពេលដែលគាត់ដោះខោអាវនោះចេញ
គាត់ក៏បានយកខោអាវធ្វើការមកពាក់នៅលើខ្លួនរបស់គាត់
យើងឃើញគាត់ស្លៀកសំពត់ពណ៌សត្រឹមជង្គង់ និងគាត់កំពុងតែពាក់អាវពណ៌
គាត់កំពុងតែពាក់អាវខៀវ គាត់កំពុងតែពាក់អាវពណ៌ខៀវដៃវែង
គាត់កំពុងតែពាក់អាវពណ៌ខៀវដៃវែង និងដើម្បីរៀបចំខ្លួនចេញទៅធ្វើការ។
អញ្ចឹងនៅពេលដែលយើងចេញទៅធ្វើការយើងត្រូវ យើងត្រូវប្ដូរសម្លៀកបំពាក់ជាមុនសិន
យើងមិនអាចស្លៀកពាក់ខោអាវគេងយប់ចេញទៅធ្វើ ចេញទៅខាងក្រៅ
ឬក៏ចេញទៅធ្វើការបានឡើយ។ អញ្ចឹងគាត់ត្រូវប្ដូរ គឺត្រូវប្ដូរពាក់ខោអាវធ្វើការ
ដើម្បីអាចចេញទៅធ្វើការបាន។ អញ្ចឹងយើងឃើញគាត់កំពុងតែ
ក្រោយពេលដែលគាត់ស្លៀកសំពត់ហើយ គាត់ក៏បានស៊កអាវចូលទៅក្នុង គាត់ក៏បានស៊កអាវ
ដើម្បីពាក់នៅលើខ្លួនរបស់គាត់ ដើម្បីពាក់នៅលើខ្លួនរបស់គាត់ និងអាចចេញទៅធ្វើការបាន។

រូបភាពទី [១០] រូបភាពទី ១២ ក្រោយពេលដែលគាត់រៀបចំខ្លួនរួចរាល់ហើយ
គាត់ក៏បានដើរតម្រង់មកកាន់តុមួយ ដែលនៅលើតុនោះយើងឃើញមានកាបូប
កាបូបរបស់គាត់គឺកាបូបយួរដៃ គឺកាបូបយួរដៃ មិនមែនកាបូបស្ពាយ
និងមិនមែនជាកាបូបស្ពាយខាងក្រោយទេ គឺជាកាបូបយួរដៃ ឬក៏កាបូបស្ពាយចំហៀង
ឬក៏កាបូបស្ពាយចំហៀង យើងឃើញនៅលើតុនោះ យើងឃើញមានកាបូប
និងយើងឃើញនៅខាងលើ យើងឃើញមានអំពូលភ្លើង ដែលចង ដែលចងព្យួរ
ដែលចងព្យួរទម្លាក់ចុះមកខាងក្រោម ប៉ុន្តែអំពូលភ្លើងនោះមិនទាន់បិទនៅឡើយទេ
អំពូលភ្លើងនោះមិនទាន់បិទនៅឡើយទេ អញ្ចឹងគាត់ក្រោយពេលដែលគាត់ស្លៀកពាក់ខោអាវហើយ
គាត់ក៏បានដើរ គាត់ក៏បានដើរមកកាន់តុនោះ ដើម្បីយកកាបូបស្ពាយចេញទៅធ្វើការ។

រូបភាពទី ១៣ ក្រោយពេលដែលគាត់រៀបចំខ្លួន រៀបចំកន្លែងគេង និងបិទភ្លើងរួចរាល់ហើយ
គាត់ក៏បានបើកទ្វារចេញទៅធ្វើការ។
យើងឃើញនៅក្បែរទ្វាររបស់គាត់យើងឃើញមានកូនតុតូចមួយ ដែលនៅលើតុនោះ
យើងឃើញមានថូផ្កា និងមានផ្កានៅក្នុងថូនោះ ដើម្បីដាក់លម្អនៅក្នុងផ្ទះ
នៅក្បែរជញ្ជាំងនៅខាងក្រោយខ្នងរបស់គាត់ យើងឃើញដូចជាមានរូបភាពមួយ រូបភាពមួយដែល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលរូបភាពនោះគឺដាក់លម្អនៅក្នុងផ្ទះរបស់គាត់
អញ្ចឹងក្រោយពេលគាត់ដើរមកយកកាបូបនៅលើតុគាត់ក៏បាន
គាត់ក៏បានស្ពាយកាបូបនោះនៅ[ចំហៀង] នៅចំហៀងដែលដាក់នៅលើស្មាដៃខាង
ដែលដាក់នៅលើស្មាដៃខាងឆ្វេងរបស់គាត់ អញ្ចឹងគាត់ស្ពាយនៅលើស្មា
និងកាន់កាបូបនោះយ៉ាងជាប់
ដោយសារតែពេលខ្លះនៅពេលដែលគាត់ដើរកាបូបនោះអាចរអិលធ្លាក់ចុះមកខាងក្រោម
អញ្ចឹងគាត់ត្រូវ អញ្ចឹងគាត់ត្រូវកាន់
អញ្ចឹងគាត់ត្រូវយកដៃគាត់កាន់កាបូបនោះកុំឲ្យវារអិលធ្លាក់ចុះមកខាងក្រោម
អញ្ចឹងគាត់ក៏បានបើកទ្វារផ្ទះ ដើម្បីដើរចេញទៅធ្វើការ ដើម្បីចេញទៅធ្វើការ។

រូបភាពទី ៩ ក្រោយពេលដែលគាត់បើកទ្វារផ្ទះចេញមក ចេញ ដើរចេញទៅធ្វើការ
អញ្ចឹងយើងឃើញគាត់ដើរនៅតាមផ្លូវ គាត់មិនបានជិះម៉ូតូឌុប ឬក៏ជិះតាក់ស៊ីទៅធ្វើការទេ
ប្រហែលជាដោយសារតែកន្លែងធ្វើការរបស់គាត់នៅជិតផ្ទះរបស់គាត់
ដូច្នេះគាត់គ្រាន់តែដើរទៅធ្វើការដោយមិនបាច់ចំណាយលុយជិះម៉ូតូ
ឬក៏ដោយមិនបានចំណាយលុយជិះម៉ូតូ ឬក៏ជិះតាក់ស៊ីទៅធ្វើការឡើយ
ពីព្រោះពេលខ្លះនៅពេលព្រឹកតាក់ស៊ីគឺផ្លូវស្ទះ ផ្លូវស្ទះ អញ្ចឹងផ្លូវស្ទះ អញ្ចឹងតាក់ស៊ី
អញ្ចឹងយើងអាចចំណាយពេលយូរ អញ្ចឹងប្រសិនបើកន្លែងការងារនៅជិតផ្ទះ អញ្ចឹងយើងអាចដើរ
[ដើម្បី] យើងអាចដើរដើម្បីហាត់ប្រាណផង អញ្ចឹង អញ្ចឹងងាយស្រួលសម្រាប់គាត់
អញ្ចឹងគាត់កំពុងតែដើរនៅតាមផ្លូវដើម្បីទៅកន្លែងធ្វើការរបស់គាត់
ប៉ុន្តែគាត់មិនទាន់ញ៉ាំអាហារពេលព្រឹកនៅឡើយទេ ប្រហែលជាគាត់ចាំទិញនៅតាមផ្លូវ
អញ្ចឹងគាត់ដើរបណ្តើរ រកមើលកន្លែងទិញអាហារពេលព្រឹកបណ្តើរ។

រូបភាពទី ១៥ រូបភាពទី ១៥ គាត់ក៏បានដើរមកដល់កន្លែងមួយ
ដែលមានលក់អាហារពេលព្រឹកនៅតាមចិញ្ចើមផ្លូវ ជាទូទៅអាហារពេលព្រឹក ជាទូទៅយើងញ៉ាំ
យើងញ៉ាំបាយសាច់ជ្រូកជាមួយនឹងពងមាន់ ឬក៏ពងទា និងពេលខ្លះគឺយើងញ៉ាំ យើងញ៉ាំមី
ឬក៏គុយទាវ មី ឬក៏គុយទាវដែលជាស៊ុប ដែល ដែលមីនោះគឺជាមីស៊ុប និងឬក៏ជាគុយទាវ
និងយើងញ៉ាំ ជាទូទៅគឺយើងអាចញ៉ាំមីឆា ឬក៏លតឆានៅពេលព្រឹកផងដែរ ពីព្រោះការចម្អិនលតឆា
មីឆា គុយទាវ ឬក៏ស៊ុបមីមិនចំណាយពេលយូរទេ មិនចំណាយពេលយូរទេ
និងគាត់អាចទិញរបស់ទាំងនោះយកទៅញ៉ាំនៅកន្លែងធ្វើការរបស់គាត់ផងដែរ។
អញ្ចឹងប្រហែលជាគាត់ទិញ ប្រហែលជាគាត់ទិញមីឆា ឬក៏គាត់ ប្រហែលជាគាត់ទិញមីឆា
ឬក៏គាត់ទិញស៊ុប ប៉ុន្តែដោយសារតែយើងឃើញនៅក្នុងរូបភាពទី ទី [១០] ទី ១៥ នេះគឺ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងឃើញមានអ្នកលក់កាន់ យើងឃើញអ្នកលក់គាត់កាន់ប្រអប់មួយ អញ្ចឹងប្រហែលជាមីឆា
អញ្ចឹងអ្នកលក់នោះគាត់លក់មីឆានៅតាមផ្លូវ គាត់លក់មីឆានៅតាមផ្លូវ ដោយមីឆាមានមីឆាសាច់គោ
ជាមួយនឹងបន្លែ និងជាមួយនឹងពងមាន់ ឬក៏ពងទា អញ្ចឹងគាត់លក់មីឆា
អញ្ចឹងក្រោយពេលដែលស្ត្រីម្នាក់នោះគាត់ដើរទៅធ្វើការ និងគាត់រក
រកកន្លែងទិញអាហារពេលព្រឹកផង
គាត់ក៏បានប្រទះឃើញកន្លែងលក់មីឆាមួយកន្លែងដែលលក់នៅតាមផ្លូវ
ដោយមានស្ត្រីចំណាស់ម្នាក់គាត់លក់មីឆានោះ អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះ យើងឃើញគាត់
យើងឃើញគាត់ ក្រោយពេល យើងឃើញគាត់កំពុងតែខ្ចប់
កំពុងតែខ្ចប់មីឆាមួយប្រអប់ឲ្យស្ត្រីម្នាក់នោះ ដោយសារតែគាត់ចង់
ដោយសារតែស្ត្រីម្នាក់នោះប្រាប់គាត់ឲ្យឆាមីជាមួយនឹងសាច់គោ ឬក៏ជាមួយនឹងពងមាន់មួយប្រអប់
អញ្ចឹងក្រោយពេលដែលស្ត្រីម្នាក់នោះបានឆា និងខ្ចប់ដាក់ និងខ្ចប់ចូលក្នុងប្រអប់រួចរាល់ហើយ
ស្ត្រីម្នាក់នោះគាត់ក៏បានសួរតម្លៃមីឆានោះ។ ជាទូទៅមីឆាដែលលក់នៅតាមផ្លូវគឺអត់ថ្លៃទេ
ប្រសិនបើយើង ឆាជាមួយនឹងសាច់គោតម្លៃ ៣០០០ ៛ ប្រសិនបើយើងឆាជាមួយតែ
ជាមួយតែពងទាទេ គឺ ២០០០ ឬក៏ ២៥០០ ៛ អញ្ចឹងប្រហែល អញ្ចឹងដោយសារតែគាត់[ឆា]
មីឆាជាមួយនឹង ជាមួយនឹងសាច់គោនិងពងទា ដូច្នេះមីឆានោះមួយប្រអប់ ៣០០០ ៛។
ក្រោយពេលអ្នកលក់ប្រាប់គាត់ [បើ] ប្រាប់តម្លៃទៅគាត់ហើយ
ស្ត្រីម្នាក់នោះគាត់ក៏បានដកលុយចេញពីកាបូបស្ពាយចំហៀងរបស់គាត់
និងបានហុចលុយឲ្យទៅអ្នកលក់ អ្នកលក់ក៏បានរៀបចំ និងដាក់ប្រអប់នោះចូលទៅក្នុងថង់
ដើម្បីងាយស្រួលឲ្យស្ត្រីម្នាក់នោះគាត់យួរទៅកាន់កន្លែងធ្វើការ។
អញ្ចឹងក្រោយពេលដែលស្ត្រីម្នាក់នោះគាត់ឲ្យលុយទៅកាន់អ្នកលក់ហើយ គាត់ក៏បាន គាត់ក៏បានយក
គាត់ក៏បានយកមីឆាពីស្ត្រីម្នាក់នោះ។

រូបភាពទី ១៦ រូបភាពទី ១៦ គាត់ក៏បានយួរមីឆានោះនៅក្នុងដៃខាងស្តាំរបស់គាត់
ដោយសារតែដៃខាងឆ្វេងរបស់គាត់ គាត់ គាត់ស្ពាយកាបូបនៅលើស្មារបស់គាត់
និងដៃរបស់គាត់កាន់កាបូបនោះជាប់
ដោយសារតែគាត់មិនចង់ឲ្យកាបូបនោះរអិលធ្លាក់ចុះមកខាងក្រោមនៅពេលដែលគាត់កំពុងតែដើរ
អញ្ចឹងគាត់ គាត់ ក្រោយពេលដែលគាត់ទិញអាហារពេលព្រឹករួចរាល់ហើយ
គាត់ក៏ដើរតម្រង់ទៅកាន់កន្លែងធ្វើការរបស់គាត់ ដែលកន្លែងធ្វើការរបស់គាត់គឺនៅជិតនេះ

អញ្ចឹង អញ្ចឹងគាត់ អញ្ចឹងរូបភាពទី ១៧ រូបភាពទី [១២]
ស្ត្រីម្នាក់នោះក៏បានដើរមកដល់កន្លែងធ្វើការរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលកន្លែងធ្វើការរបស់គាត់គឺនៅអគារដ៏ធំមួយ នៅអគារដ៏ធំមួយ ដែលអគារនោះគឺចំរុះទៅដោយ
គឺចំរុះទៅដោយ ចំរុះទៅដោយក្រុមហ៊ុនផ្សេងៗ ឬក៏ការិយាល័យផ្សេងៗជាច្រើន។
អញ្ចឹងដែលការិយាល័យ ឬក៏ក្រុមហ៊ុនទាំងអស់នោះ ដែលមកពី ដែលក្រុមហ៊ុនទាំងអស់នោះ
បានមកធ្វើការ និងបានមកជួលទីតាំងនៅក្នុងអគារនោះ បានមកជួលទីតាំងនៅក្នុងអគារនោះ
អញ្ចឹងយើងឃើញអគាររបស់គាត់គឺ គឺមានទ្វារកញ្ចក់ និងមានកាំជណ្ដើរពីរកាំ
អញ្ចឹងគាត់ក៏បានដើរតម្រង់ទៅកាន់ទ្វារនោះដើម្បីបើកទ្វារចូលទៅក្នុង[កន្លែង] ចូលទៅក្នុង
ចូលទៅខាងក្នុងដើម្បីដើរទៅកន្លែងធ្វើការរបស់គាត់។ អញ្ចឹងគាត់អត់ទាន់ញ៉ាំ អញ្ចឹងនៅ
អញ្ចឹងគាត់អត់ទាន់ញ៉ាំអាហារពេលព្រឹករបស់គាត់នៅឡើយទេ
គាត់រង់ចាំនៅពេលដែលគាត់ដើរទៅដល់កន្លែងធ្វើការ និងនៅពេលដែលគាត់អង្គុយ
នៅពេលដែលគាត់អង្គុយ គាត់អាចញ៉ាំអាហារពេលព្រឹកដែលគាត់បានទិញនៅតាមផ្លូវនោះ។
អញ្ចឹងគឺងាយស្រួល អញ្ចឹងនៅពេលព្រឹកគាត់មិនចាំបាច់ចម្អិនអាហារដោយខ្លួនឯងទេ
គាត់គ្រាន់តែទិញអាហារនៅតាមផ្លូវ និងដើរមកធ្វើការ និងអាចញ៉ាំនៅកន្លែងធ្វើការបាន
ជាទូទៅអ្នកក្រុងនិងអ្នកស្រែអាហារពេលព្រឹកខុសគ្នាបន្តិច ខុសគ្នា
នៅទីក្រុងអាហារពេលព្រឹកពួកគាត់គឺញ៉ាំគុយទាវ មីឆា បាយឆា បាយសាច់មាន់
ឬក៏បាយសាច់ជ្រូកជាមួយពងមាន់ ឬក៏ពងទា ប៉ុន្តែអ្នកដែលរស់នៅតាមជនបទ ឬក៏ស្រុកស្រែចំការ
នៅពេលព្រឹកគឺគាត់ត្រូវចម្អិនអាហាររបស់គាត់ដោយខ្លួនឯង ឬក៏នៅពេលព្រឹកគឺគាត់ញ៉ាំបាយកក។
បាយកកគឺ គឺជាបាយដែលសល់ពីល្ងាច គឺគាត់មិនបានដាំពេលព្រឹកទេ គឺជាបាយដែលសល់ពីល្ងាច
ដូច្នេះយើងហៅថាបាយកក។ អញ្ចឹងគាត់ គាត់ គាត់ហូបបាយកកទាំងអស់នោះ
គាត់ហូបបាយកកជាមួយនឹងពងមាន់ ឬក៏ពងទា ឬក៏ជាមួយត្រីដែលគាត់រកបាន
អញ្ចឹងគាត់អត់[ស្ទូវ]នៅ ភាគច្រើននៅជនបទអត់សូវសម្បូរម្ហូប ឬក៏អត់ អត់សូវសម្បូរម្ហូប
ឬក៏កន្លែងលក់ កន្លែងលក់អាហារ កន្លែងលក់បាយ ឬក៏ម្ហូប ឬក៏អាហារនៅតាមចិញ្ចើមផ្លូវទេ
ដោយសារតែនៅតាមស្រុកស្រែ ឬក៏ជនបទ គឺពួកគាត់មិនសូវមានលុយច្រើន
ដូច្នេះគាត់ត្រូវចាយសន្សំសំចៃ គាត់ត្រូវចាយសន្សំសំចៃដោយសារតែគាត់មានស្រូវ
និងអង្ករនៅផ្ទះរបស់គាត់ហើយ ដូច្នេះគាត់គ្រាន់តែចេញទៅរក គាត់គ្រាន់តែចេញទៅរកត្រី
ឬក៏មាន់ទាដែលគាត់ចិញ្ចឹមនោះ មាន មានពង ដូច្នេះគាត់អាចប្រើពងមាន់
ឬក៏ពងទានោះមកចម្អិនម្ហូបសម្រាប់អាហារពេលព្រឹករបស់គាត់។ អញ្ចឹងខុសគ្នាពីអ្នកទីក្រុង
អ្នកទីក្រុងពេលព្រឹកឡើង ប្រសិនបើគាត់ខ្ជិលចម្អិនអាហារទេ គាត់គ្រាន់តែចេញទៅខាងក្រៅទិញ
ទៅទិញអាហារនៅតាមចិញ្ចើមថ្នល់ និងអាហារតាមចិញ្ចើមថ្នល់គឺឆ្ងាញ់ និងមានតម្លៃថោក អត់ថ្លៃទេ
និងគាត់អាចញ៉ាំនៅកន្លែងធ្វើការរបស់គាត់បានយ៉ាងងាយស្រួល។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.